**ប្រការ ២** : ក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co ltd ត្រូវដំណើរការ ការងារសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែ លើផ្ទៃដីដែលបានកំណត់នេះដោយធានានូវលក្ខ ការណ៍ បច្ចេកទេស ភូគព្ភសាស្ត្រ ។

**ប្រការ ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេល ២ (ពីរ) ឆ្នាំ ។ ផុតកំណត់ពេលនេះ ក្រុមហ៊ុនត្រូវដាក់ពាក្យ សុំការអនុញ្ញាតធ្វើប្រតិបត្តិការសិក្សា ស្រាវជ្រាវស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានល័ក្ខខ័ណ្ឌ ។

**ប្រការ ៤** : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ-រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច ប្រធានមន្ទីរ ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តរតនគីរី និង ប្រធានក្រុមហ៊ុនត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ។ ខ្លួន ។

**ប្រការ ៥** : ប្រកាសមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ពូ សុធីរៈ**

* * *

ភ្នំពេញ , ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

## ប្រកាសលេខ ៨០២ ឧរ . ប្រក

## អនុញ្ញាតអោយក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT. CO,.LTD ធ្វើប្រតិបត្តិការសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែ នៅតំបន់អូរយ៉ាដាវលើ ស្រុកអូរយ៉ាដាវ ខេត្ត រតនគីរី

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញលិខិតអនុញ្ញាតជាគោលការណ៍ របស់គណកម្មាធិការវិនិយោគ កម្ពុជា លេខ ៨១៩ /៩៥ គវិក ចុះថ្ងៃទី ១៤-៩-១៩៩៥
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុន សិក្សាស្រាវជ្រាវស្វែងរុករក ធនធានរ៉ែ នៅតំបន់ អូរយ៉ាដាវលើ-ក្រោម ខេត្តរតនគិរី ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៥
- បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតសិក្សាស្រាវជ្រាវស្វែងរុករកធនធាន រ៉ែ របស់ក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co.ltd លេខ ១៤/៩៥ ក.ស ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥

**សម្រេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co ltd មានអាស័យដ្ឋានផ្ទះលេខ ២៥៨ ផ្លូវ ១៥៦ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ធ្វើប្រតិបត្តិការសិក្សា ស្រាវជ្រាវស្វែងរុករកធនធានរ៉ែនៅតំបន់អូរយ៉ាដាវលើ ក្រោម ខេត្តរតនគិរី លើផ្ទៃដី ៥០៤ គីឡូម៉ែត្រក្រឡា មានកូអរដោណេដូចតទៅ ÷

| ចំណុច | ខ្សែរយៈទទឹង | ខ្សែរយៈបណ្តោយ |
|---|---|---|
| A | 107°22'11"E | 13°38'32"N |
| B | 107°33'55"E | 13°38'32"N |
| C | 107°33'55"E | 13°25'30"N |
| D | 107°22'11"E | 13°25'30"N |

**ប្រការ ២** : ក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co ltd ត្រូវដំណើរការ ការងារសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែ លើផ្ទៃដីដែលបានកំណត់នេះដោយធានានូវលក្ខ ការណ៍ បច្ចេកទេស ភូគព្ភសាស្ត្រ ។

**ប្រការ ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេល ២ (ពីរ) ឆ្នាំ ។ ផុតកំណត់ពេលនេះ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំការអនុញ្ញាត ធ្វើប្រតិបត្តិការសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានលក្ខខ័ណ្ឌ ។

**ប្រការ ៤** : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ-រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច ប្រធានមន្ទីរ ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តរតនគិរី និង ប្រធានក្រុមហ៊ុនត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ។ ខ្លួន ។

**ប្រការ ៥** : ប្រកាសមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**ពូ សុធីរៈ**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

## ប្រកាសលេខ ៨០៣ ឧក.ប្រក

**ប្រការ ១** : អនុញ្ញាតអោយលោក **ខិវន់ ខុំ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៨៧៤១ ត.ក ចុះថ្ងៃទី ១៩-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ គុសថ្មី ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ បើកដំណើរការ

រោង ម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំងភូមិ ត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុក ត្រាំកក់ ខេត្តតាកែវ ។

**ប្រការ ២ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ៨០៤ ឧក.ប្រក**

**ប្រការ ១ :** អនុញ្ញាតអោយលោក **ហ៊ុន ឡូត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ៣៨០៣៥៣.ក.ប ចុះថ្ងៃទី ២៩-៤-៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិប្រតាប ឃុំរូងជ្រៃ ស្រុក បាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២ :** លោក **ហ៊ុន ឡូត** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុង ប្រការ ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការ ប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។